ស្ថានទូតអូស្ត្រាលីប្រចាំនៅ
ព្រះរាជាណាចក្រកម្ពុជា

សេចក្តីប្រកាសព័ត៌មាន

**ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២១**

## ការស្រាវជ្រាវរបស់អូស្ត្រាលី ដើម្បីបង្កើនការវិនិយោគ និងនវានុវត្តន៍ ក្នុងវិស័យទឹកស្អាត

ថ្ងៃនេះ លោក Luke Arnold ភារធារីស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា បានជួបជាមួយ ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី លើការទទួលបានទឹកស្អាតប្រើប្រាស់របស់ប្រជាពលរដ្ឋនៅតាមបណ្តាខេត្តនានា ក្នុងប្រទេសកម្ពុជា។

នៅក្នុងជំនួបនេះ លោក Arnold បានសង្ខេបពី របកគំហើញនៃការស្រាវជ្រាវ និងការវិភាគចុងក្រោយលើបណ្តាញទឹកស្អាតនៅតាមខេត្តនានា ដែលមានឈ្មោះថា *ភីអាយភី* ទៅដល់ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ។ ការសិក្សាផែនការវិនិយោគខេត្ត (ភីអាយភី)នេះ បង្ហាញថា ខណ:ដែលមានតែ ៤៧% នៃភូមិទាំងអស់នៅកម្ពុជា មានបណ្តាញទឹកស្អាតនៅត្រឹមឆ្នាំ ២០២០ តួលេខនៃបណ្តាញទឹកស្អាតនេះ អាចកើនឡើងយ៉ាងឆាប់រហ័សតាមរយ:កិច្ចសហប្រតិបត្តិការនិងភាពជាដៃគូរវាង ស្ថាប័នសាធារណៈ និង ឯកជន ដើម្បីបង្កើនការវិនិយោគនិងនវានុវត្តន៍ ពីសំណាក់វិស័យឯកជន សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត។

លោក Arnold មានប្រសាសន៍ថា "អូស្ត្រាលីនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីអភិវឌ្ឍវិស័យទឹកស្អាតបន្ថែមទៀត នេះក៏ព្រោះតែផលប៉ះពាល់ដោយផ្ទាល់ទៅលើសុខភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅពេលដែលពួកគាត់មានទឹកស្អាតប្រើប្រាស់នៅផ្ទះ"។ ការសិក្សាដ៏មានសារ:សំខាន់នេះ បានបង្ហាញពីកាឡានុវត្តភាពសំខាន់ៗនានា ដើម្បីពង្រីកការផ្គត់ផ្គង់ទឹកស្អាត ក្រោមកិច្ចសហការ និងភាពជាដៃគូ រវាងស្ថាប័នសាធារណៈ និង ឯកជន។

លោក Arnold ក៏បានពន្យល់បន្ថែមទៀតថា ការរួមចំណែករបស់ស្ថានទូតអូស្ត្រាលីទៅលើបណ្តាញទឹកស្អាតកម្ពុជា មានសង្គតភាពទៅនឹងកម្មវិធីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់អូស្ត្រាលី នៅកម្ពុជា រួមទាំងការផ្តល់អាទិភាពដល់គម្រោងមួយចំនួន ដែលត្រូវបានគាំទ្រថវិកា ប្រកបដោយចីរភាព និង ដែលផ្តល់នូវផលប្រយោជន៍ពិតប្រាកដសម្រាប់ពលរដ្ឋនៅកម្ពុជា។

ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ បានថ្លែងនៅក្នុងព្រឹត្តិការណ៍នោះថា "រដ្ឋាភិបាលគ្រោងនឹងផ្តល់ទឹកស្អាត ១០០% ដល់ពលរដ្ឋនៅទីប្រជុំជននៅត្រឹមឆ្នាំ ២០២៥ ហើយផ្តល់ទឹកស្អាតដល់ប្រជាជនកម្ពុជាទាំងអស់ នៅត្រឹមឆ្នាំ

២០៣០។ ដោយមានប្រព័ន្ធទិន្នន័យ ដែលកម្មវិធី 3i  បានអភិវឌ្ឍ ជាមួយអគ្គនាយកផ្គត់ផ្គង់ទឹកស្អាតរបស់ក្រសួងយើង ខ្ញុំជឿជាក់ថាយើងកំពុងស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវដើម្បីសម្រេចបាននូវគោលដៅនេះ។ ខ្ញុំសូមថ្លែងអំណរគុណដល់អូស្ត្រលី ចំពោះជំនួយនិងការងារទាំងអស់ដែលបានផ្តល់មកកាន់ក្រសួង។”

ការសិក្សាស្រាវជ្រាវមួយនេះ ត្រូវបានធ្វើឡើងដោយកម្មវិធីរបស់អូស្ត្រាលី “វិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i)” ដែលកម្មវិធីទាំងមូលមានទឹកប្រាក់ចំនួន ៩៩ លានដុល្លារអូស្ត្រាលីនៅក្នុងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះបានវាយតម្លៃវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅទូទាំងខេត្តចំនួន ២២ របស់ប្រទេសកម្ពុជា ហើយគណនាទឹកប្រាក់វិនិយោគសរុបដើម្បីផ្គត់ផ្គង់ទឹកស្អាតទៅកាន់ភូមិទាំងអស់នៅកម្ពុជាដែលមិនទាន់មានបណ្តាញទឹកស្អាតដើម្បីប្រើប្រាស់។

តាមរយៈកម្មវិធី3i អូស្ត្រាលីបានអនុម័ត និងវិនិយោគថវិកាជាង ១៩,៨ លានដុល្លារអូស្ត្រាលីដល់ប្រតិបត្តិករទឹកឯកជនចំនួនជិត ៨០ ដើម្បីបង្កើត និងពង្រីកការផ្គត់ផ្គង់ទឹកស្អាត ដល់គ្រួសារជនបទ។ នៅពេលដែលកម្មវិធីនេះបញ្ចប់ ពលរដ្ឋកម្ពុជាជាងមួយលាននាក់ នឹងមានទឹកស្អាតប្រើប្រាស់ដោយសារកម្មវិធី3i។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ Australian.Embassy.Cambodia@dfat.gov.au